## ទីក្រុងឡុងប៊ិច
## ការវិភាគមិនលំអៀងរបស់មេធាវីក្រុង នៃវិធានការ LBC

### វិសោធនកម្មធម្មនុញ្ញ ដើម្បីសម្រប/ស៊ីសង្វាក់តាមកាលបរិច្ឆេទនៃការបោះឆ្នោតបឋម និងការបោះឆ្នោតទូទៅរបស់ទីក្រុង ជាមួយនឹងកាលបរិច្ឆេទបោះឆ្នោតបឋម និងការបោះឆ្នោតទូទៅរបស់រដ្ឋ ដែលបានប្រព្រឹត្តឡើងក្នុងឆ្នាំដែលមានលេខគូរ

នៅថ្ងៃទី 9 ខែសីហា ឆ្នាំ 2022 ក្រុមប្រឹក្សាក្រុងឡុងប៊ិចបានដាក់វិធានការ LBC នៅលើសន្លឹកឆ្នោត។ វិធានការនេះនឹងធ្វើវិសោធនកម្មធម្មនុញ្ញទីក្រុងឡុងប៊ិច ដើម្បីស៊ីសង្វាក់តាមកាលបរិច្ឆេទនៃការបោះឆ្នោតបឋម និងការបោះឆ្នោតទូទៅរបស់ទីក្រុង ជាមួយនឹងកាលបរិច្ឆេទបោះឆ្នោតបឋម និងការបោះឆ្នោតទូទៅរបស់រដ្ឋ ដែលបានប្រព្រឹត្តឡើងក្នុងឆ្នាំដែលមានលេខគូរ។

ធម្មនុញ្ញទីក្រុង ផ្នែកទី1901 បច្ចុប្បន្ននេះតម្រូវឱ្យទីក្រុងរៀបចំការបោះឆ្នោតបឋមទីក្រុងរបស់ខ្លួន នៅថ្ងៃអង្គារអាទិត្យទីពីរ ក្នុងខែមេសា នៅក្នុងឆ្នាំដែលមានលេខគូ និងការបោះឆ្នោតក្រុងទូទៅរបស់ខ្លួននៅថ្ងៃអង្គារអាទិត្យដំបូង បន្ទាប់ពីថ្ងៃចន្ទ អាទិត្យទីមួយ ក្នុងខែមិថុនា ក្នុងឆ្នាំដែលមានលេខគូ។ ផងដែរ ផ្នែកទី 1901 ក៏ចែងថា បេក្ខជនជាប់ឆ្នោតចូលកាន់តំណែងនៅថ្ងៃអង្គារអាទិត្យទីបី ក្នុងខែកក្កដា។

វិធានការនេះ នឹងធ្វើវិសោធនកម្មផ្នែកទី 1901 នៃធម្មនុញ្ញទីក្រុង ដើម្បីកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតក្រុងរបស់ទីក្រុងឱ្យស៊ីសង្វាក់តាមការបោះឆ្នោតបឋម និងការបោះឆ្នោតទូទៅរបស់រដ្ឋ។ ការបោះឆ្នោតបឋមរបស់រដ្ឋ ប្រព្រឹត្តទៅនៅក្នុងខែមីនាសម្រាប់ឆ្នាំបឋមនៃការបោះឆ្នោតប្រធានាធិបតី និងនៅក្នុងខែមិថុនា សម្រាប់ការបោះឆ្នោតបឋមនៃការបោះឆ្នោតជ្រើសរើសអភិបាលរដ្ឋឡើងវិញ។ ការបោះឆ្នោតទូទៅរបស់រដ្ឋប្រព្រឹត្តទៅនៅក្នុងខែវិច្ឆិកា សម្រាប់ទាំងការបោះឆ្នោតជ្រើសរើសប្រធានាធិបតី និងការបោះឆ្នោតជ្រើសរើសអភិបាលរដ្ឋឡើងវិញ។

ដោយសារវិធានការនេះ តម្រូវឱ្យការបោះឆ្នោតទូទៅប្រព្រឹត្តទៅក្នុងខែវិច្ឆិកា, ផងដែរ ផ្នែកទី 1901 ក៏នឹងត្រូវបានធ្វើវិសោធនកម្ម ដើម្បីផ្តល់ឱ្យបេក្ខជនដែលជាប់ឆ្នោតឱ្យចូលកាន់តំណែងនៅថ្ងៃអង្គារអាទិត្យទីបីក្នុងខែធ្នូ ឬនៅពេលបន្ទាប់នោះតាមការចាំបាច់ ដើម្បីធ្វើការប្រមូល និងបញ្ជាក់លទ្ធផលនៃការបោះឆ្នោតនាខែវិច្ឆិកា។

ការបោះឆ្នោត "បាទ/ចាស" នឹងបណ្តាលអោយខោនធីឡូសអានជឺឡេស ដំណើរការក្នុងការបោះឆ្នោតរបស់ទីក្រុង ដែលនឹងមានផលប៉ះពាល់ដល់សារពើពន្ធ/ថវិកាឡើងវិញ ដែលត្រូវបានប៉ាន់ប្រមាណថាមានចំនួនសរុប 3.1 លានដុល្លារ សម្រាប់ការបោះឆ្នោតបឋម និងការបោះឆ្នោតទូទៅ, ដែលជាទូទៅ ឆ្លុះបញ្ចាំងពីការចំណាយលើការគ្រប់គ្រងការបោះឆ្នោតបច្ចុប្បន្នរបស់ទីក្រុង។

ការបោះឆ្នោត "ទេ" ទំនងជានឹងបណ្តាលឱ្យទីក្រុងដំណើរការការបោះឆ្នោតដោយខ្លួនឯង ដែលនឹងមានផលប៉ះពាល់ដល់សារពើពន្ធម្តងទៀត ដែលរួមបញ្ចូលការចំណាយសរុបចំនួន 4.4 លានដុល្លារ សម្រាប់ការបោះឆ្នោតបឋម និងទូទៅ និងការចំណាយតែម្តងចំនួន 2.5 លានដុល្លារ ដើម្បីទទួលបាននូវឧបករណ៍ផ្សេងៗ។ គ្រឿងបរិក្ខារ និងបុគ្គលិកគឺចាំបាច់ណាស់សម្រាប់ទីក្រុង ដើម្បីដំណើរការនៃការបោះឆ្នោតរបស់ខ្លួន។

ការបោះឆ្នោត "បាទ/ចាស" គឺគាំទ្រដល់ការបោះឆ្នោតរបស់ទីក្រុងដែលសម្របតាមកាលបរិច្ឆេទបោះឆ្នោតរបស់រដ្ឋ។

ការបោះឆ្នោត "ទេ" គឺទីក្រុងប្រឆាំងជំទាស់ មិនសម្របការបោះឆ្នោតតាមកាលបរិច្ឆេទបោះឆ្នោតរបស់រដ្ឋ និងរក្សាកាលបរិច្ឆេទការបោះ

ឆ្នោតទីក្រុងដែលមានស្រាប់ អោយនៅដដែល។

តម្រូវអោយមានសំឡេងភាគច្រើន បោះឆ្នោត "បាទ/ចាស" ដើម្បីឱ្យវិធានការនេះអនុម័ត/ឈ្នះ។

**សេចក្តីថ្លែងការណ៍ខាងលើនេះ គឺជាការវិភាគមិនលំអៀងចំពោះវិធានការ LBC។ ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃវិធានការនេះ សូមទូរស័ព្ទទៅកាន់ការិយាល័យស្មៀនក្រុង តាមលេខ 562-570-6101 ហើយច្បាប់ចម្លងនេះ នឹងត្រូវបានផ្ញើទៅអោយអ្នកដោយឥតគិតថ្លៃ។**

CHARLES PARKIN
មេធាវីក្រុងឡុងប៊ិច